# ពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍

BUDDHISM FOR DEVELOPMENT

ភូមិស្រះឈូក សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ

Tel: 012 67 74 98 /097 73 43 063

E-mail: bfdpvh@bfdkhmer.org


---

## របាយការណ៍សង្ខេប

## ការចុះប្រមូលព័ត៌មាន និងទិន្នន័យបន្ថែម

*(ចាប់ពីថ្ងៃទី១៩ ដល់ ២១ ខែសីហា ឆ្នាំ២០១៥)*

### ១. សាវតានៃគម្រោង

GFA ដែលជាក្រុមហ៊ុននាំមុខគេមួយ ជារួមមានក្រុមហ៊ុន Sequa ប្រទេសអាល្លឺម៉ង់ និងអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ (BFD) ជាដៃគូ និងក្រុមហ៊ុនម៉ៅការមួយចំនួន, រួមបញ្ចូលទាំងអង្គការអភិវឌ្ឍន៍ប្រទេសស៊ុយអ៊ែត "HELVETAS" និងសណ្ឋាគារនៅប្រទេសស្វីស បានបង្កើតសមាគមមួយសម្រាប់អនុវត្តនូវជំនាញរបស់គម្រោងអភិវឌ្ឍន៍ជំនាញកម្ពុជា (Skill Development Program (SDP)) តំណាងឲ្យទីភ្នាក់ងារស្វីសដើម្បីការអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការ ។ SDP ត្រូវបានរំពឹងថា នឹងចូលរួមចំណែកដល់ការពង្រីកសកម្មភាពអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេស (TVET) មួយដែលបង្កើននូវដំណើរការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការធ្វើឱ្យប្រសើរឡើងនូវឱកាសការងារដល់យុវជនក្រីក្រដែលជួបការលំបាកនៅតាមទីជនបទ ។ អង្គការ ពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍ នេះត្រូវបានគេជ្រើសរើសជាដៃគូក្នុងស្រុក និងវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ដែលទទួលខុសត្រូវក្នុងការចុះស្រង់ព័ត៌មាន និងទិន្នន័យនៅក្នុងខេត្តគោលដៅទាំង៣ មានខេត្តព្រះវិហារ, ស្ទឹងត្រែង និងក្រចេះ។

### ២. គោលបំណងនៃការស្រង់ព័ត៌មានបន្ថែម

បន្ទាប់ពីការវិភាគលើលទ្ធផលចុះប្រមូលព័ត៌មានលើកទី១ ដែលប្រព្រឹត្តទៅ ចាប់ពីថ្ងៃទី១៥ ខែមិថុនា ដល់ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៥ កន្លងមក នៅមានការខ្វះខាតព័ត៌មានមួយចំនួន ជាពិសេសលើស្ថានភាពសេដ្ឋកិច្ច និងទីផ្សារការងារក្នុងខេត្តព្រះវិហារ ដូច្នេះក្រុមការងាររបស់គម្រោងអភិវឌ្ឍន៍ជំនាញកម្ពុជា (SDP) ដែលសម្របសម្រួលដោយវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា (CDRI) សហការជាមួយអង្គការពុទ្ធសាសនា ដើម្បីអភិវឌ្ឍន៍ (BFD) ចុះប្រមូលទិន្នន័យបន្ថែម នៅតាមមន្ទីរ/ស្ថាប័នពាក់ព័ន្ធ និងសហគ្រាសមួយចំនួន ចាប់ពីថ្ងៃទី១៧ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៥ ។

### ៣. ការចុះជួបសម្ភាសន៍នៅតាម មន្ទីរ/ស្ថាប័ន/អាជីកម្ម/សហគ្រាស/NGOs

ដើម្បីទទួលបានព័ត៌មានកាន់តែច្បាស់ គម្រោងអភិវឌ្ឍន៍ជំនាញកម្ពុជា( SDP) ដែលសម្របសម្រួលក្នុងការចុះប្រមូលព័ត៌មានដោយ CDRI សហការជាមួយអង្គការពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍ (BFD) បានជ្រើសរើសមន្ទីរ/ស្ថាប័នពាក់ព័ន្ធមួយចំនួនដែលកំពុង អនុវត្តការងារក្នុងខេត្តព្រះវិហារ មានដូចជា៖

*តារាងឈ្មោះមន្ទីរ/ស្ថាប័ន/អាជីវកម្ម/សហគ្រាស/NGOs*

| ល.រ | មន្ទីរ/ស្ថាប័ន/អាជីវកម្ម | ចំនួនអ្នកផ្តល់បទសម្ភាសន៍ | ផ្សេងៗ |
|---|---|---|---|
| ១ | មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៣ | |
| ២ | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ | ១ | |
| ៣ | មន្ទីរទេសចរណ៍ | ៣ | |
| ៤ | មន្ទីរកិច្ចការនារី | ២ | |
| ៥ | រដ្ឋបាលសាលាខេត្ត | ១ | |
| ៦ | ហាងលក់គ្រឿងសំណង់ | ២ | |
| ៧ | សភាពាណិជ្ជកម្ម | ១ | |
| ៨ | ស្ថាប័នហិរញ្ញវត្ថុ (ធនាគារភូមិ) | ១ | |
| ៩ | ភោជនីយដ្ឋាន | ១ | |
| ១០ | អង្គការជនជាតិដើមភាគតិច គួយ (OPKC) | ២ | |
| ១១ | មន្ទីរផែនការ | ១ | |
| ១២ | អង្គការពន្លកខ្មែរ (PKH) | ២ | |
| | សរុប | ២០នាក់(ស្រី២) | |

## ៤. គម្រូវសំណួរប្រមូលព័ត៌មានបន្ថែម

Rapid Market Assessment

Question guide

**ផ្នែកទី១៖ ព័ត៌មានរបស់អ្នកផ្តល់សម្ភាសន៍**

ឈ្មោះ:........................................................................ភេទ:........................................................................

ការងារ:........................................................................បទពិសោធន៍:........................................................................

ព័ត៌មានអំពីអាជីវកម្ម/មុខរបរ (ប្រភេទ...ចំនួនបុគ្គលិក(ភេទ)...ផ្សេងៗ) –សម្រាប់វិស័យឯកជន

..........................................................................................................................................................

..........................................................................................................................................................

**ផ្នែកទី២៖ សំនួរ**

1. **ឱកាសការងារ**
   1.1. សូមរៀបរាប់អំពីឱកាសការងារដែលមាននៅខេត្តរបស់លោកអ្នក។
   1.2. ឱកាសការងារភាគច្រើនមាននៅទីកន្លែងណា?
   1.3. តើឱកាសការងារប្រភេទណាខ្លះដែលយុវជន (15-30ឆ្នាំ) អាចងាយរកបាននៅខេត្តរបស់លោកអ្នក?
   1.4. សូមរៀបរាប់អំពីឱកាសការងារដែលអ្នកគិតថាមានសក្តានុពលអាចមានការរីកចំរើននាពេលអនាគត?
   1.5. តាមគំនិតយោបល់របស់អ្នក អំពីឱកាសការងារដែលអ្នកគិតថាមានសក្តានុពល អាចមានការរីកចំរើននាពេលអនាគត តើជំនាញអ្វីដែលអាចជាតម្រូវការរបស់ឱកាសការងារនោះ?
   1.6. តាមគំនិតយោបល់របស់អ្នក តើអ្វីខ្លះ ដែលអាចជា -ឧបសគ្គចំពោះឱកាសការងារ ដែលអ្នកគិតថាមានសក្តានុពលទាំងនោះ?
   1.7. បើតាមការប៉ាន់ស្មានរបស់អ្នក តើការងារចំនួនប៉ុន្មាន ដែលនឹងអាចមាននៅខេត្តរបស់អ្នក? (មួយឆ្នាំខាងមុខ)
2. **ឱកាសអាជីវកម្ម**
   2.1. តើលោកអ្នកគិតថា នៅតំបន់របស់លោកអ្នក អាចមានឱកាសបង្កើតមុខរបរថ្មី (អាជីវកម្ម) ឬទេ? សូមរៀបរាប់ពីអាជីវកម្ម។
   2.2. តើលោកអ្នកគិតថាជំនាញអ្វី ដែលត្រូវការសម្រាប់មុខរបរដែលបង្កើតថ្មីទាំងនោះ? សូមរៀបរាប់។
   2.3. តើលោកអ្នកគិតថា អាចមានឧបសគ្គចំពោះការបង្កើតមុខរបរថ្មីឬទេ? សូមរៀបរាប់។
3. **គម្រោងអាជីវកម្ម និង ហេដ្ឋារចនាសម្ព័ន**
   3.1. នៅក្នុងខេត្តនេះ តើនៅកន្លែងណាខ្លះដែលលោកអ្នកគិតថាមានសក្តានុពលភាពសេដ្ឋកិច្ច?
   3.2. តើអាជីវកម្មធំៗឋិតនៅកន្លែងណានៅក្នុងតំបន់នេះ?(ប្រភេទអាជីវកម្ម និងទីកន្លែង)
   3.3. តើគម្រោងអាជីវកម្មធំៗសម្រាប់ឆ្នាំក្រោយនៅតំបន់នេះឋិតនៅកន្លែងណា?
   3.4. តើគម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗអ្វីខ្លះ ដែលនឹងធ្វើឡើងសម្រាប់ទ្រទ្រង់ការអភិវឌ្ឍសេដ្ឋកិច្ចនៅខេត្តរបស់អ្នក?

## ៥. បញ្ហាជួបប្រទះ

- មានរយៈពេលខ្លីក្នុងការផ្តល់ព័ត៌មាន
- ពួកគាត់ជាប់រវល់ការងារក្នុងអង្គភាពច្រើន
- ព័ត៌មានមួយចំនួន ពួកគាត់ពុំអាចដឹងច្បាស់លាស់

## ៦. កិច្ចសហការនិងគាំទ្រ

- គ្រប់មន្ទីរជុំវិញខេត្ត មានកិច្ចសហការល្អរវាងអង្គការដៃគូអភិវឌ្ឍន៍
- គ្រប់មន្ទីរ/ស្ថាប័នពាក់ព័ន្ធបានគាំទ្រនូវសកម្មភាពអភិវឌ្ឍន៍ជំនាញ
- ពួកគាត់ពេញចិត្តក្នុងការផ្តល់ព័ត៌មាននូវអ្វីដែលពួកគាត់បានដឹង

## ៧. សេចក្តីសន្និដ្ឋាន

ក្រុមបុរស និងស្ត្រី ដែលបោះបង់ការសិក្សា និងក្រីក្រ និងជនងាយរងគ្រោះ នឹងមានឱកាសចូលរួមជាមួយគម្រោងអភិវឌ្ឍន៍ជំនាញ ហើយពួកគេនឹងទទួលបាននូវចំណេះដឹងផ្នែកជំនាញផ្ទាល់ខ្លួនបន្ថែម ដើម្បីយកទៅប្រកបមុខរបរក្នុងការស្តួយជីវភាពគ្រួសារបានកាន់តែប្រសើរឡើងនាពេលអនាគត ។

ធ្វើនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៥

អ្នកធ្វើរបាយការណ៍

**ម៉ែន វណ្ណារា**

<u>សកម្មភាពចុះសម្ភាសន៍តាមមន្ទីរ និងស្ថាប័នពាក់ព័ន្ធ</u>











